17087

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិដឹកនាំការងារ**
**កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ**
លេខ ...០៧៥ សសរ.../គ.ជ.រ.វ

# សេចក្តីសម្រេច
## ស្តីពីការបង្កើតអនុគណៈកម្មការនានាចំណុះ
## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងសេចក្តីសម្រេចលេខ ០៤៨ សសរ/គ.ជ.រ.វ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងសេចក្តីសម្រេច របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការលេខ ០៤៩ សសរ/គ.ជ.រ.វ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ក្រុមការងារ នៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងស្មារតីអង្គប្រជុំលើកទី៣ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧។

## សម្រេច
## ជំពូកទី ១
## អំពីអនុគណៈកម្មការ

**ប្រការ ១.-**

ត្រូវបានបង្កើតអនុគណៈកម្មការចំនួន៥ ចំណុះគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហ

មជ្ឈការ "គ.ជ.វ.វ" រួមមាន ÷

- អនុគណៈកម្មការមុខងារ និងស្ថាប័ន
- អនុគណៈកម្មការសារពើពន្ធ និងហិរញ្ញវត្ថុ
- អនុគណៈកម្មការផែនការ
- អនុគណៈកម្មការនគរូបនីយកម្ម និងព្រំប្រទល់
- អនុគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ធនធានមនុស្ស

## ជំពូកទី ២

## សមាសភាព និងតួនាទី ភារកិច្ចរបស់អនុគណៈកម្មការនៃ គ.ជ.វ.វ

**ប្រការ ២.-**

អនុគណៈកម្មការនានានៃ គ.ជ.វ.វ មានតួនាទីជាជំនួយការ និងផ្តល់យោបល់ជូន គ.ជ.វ.វ អំពី ÷

- ការតាក់តែងច្បាប់រៀបចំអង្គការសម្រាប់ថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។
- ការគាំទ្រដល់ថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិក្នុងដំណើរការកំណែទម្រង់នយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។
- ការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីគាំទ្រដល់ដំណើរការកំណែទម្រង់ខាងលើ ។

**ប្រការ ៣.-**

អនុគណៈកម្មការមុខងារ និងស្ថាប័នមានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២. | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣. | តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. | តំណាង ក្រសួងកិច្ចការនារី | សមាជិក |
| ៥. | តំណាង ក្រសួងផែនការ | សមាជិក |
| ៦. | តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧. | តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៨. | តំណាង ក្រសួង ស្ថាប័នពាក់ព័ន្ធ តាមការចាំបាច់ | សមាជិក |
| ៩. | តំណាងលេខាធិការដ្ឋាននៃ គ.ជ.វ.វ | ផ្នែកលេខាធិការ |

តំណាងក្រសួង ស្ថាប័ន ដែលជាសមាជិកអនុគណៈកម្មការ ត្រូវមានឋានៈចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ។

អនុគណៈកម្មការមុខងារ និងស្ថាប័នមានតួនាទី ភារកិច្ចដូចខាងក្រោម ÷

ក. រៀបចំគោលនយោបាយនានាក្នុងការរៀបចំស្ថាប័ន និងការប្រគល់មុខងារទៅឱ្យថ្នាក់រដ្ឋបាលនានា នៅក្រោមថ្នាក់ជាតិ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់រៀបចំអង្គការដោយ ÷

- ពិនិត្យមើលឡើងវិញនូវមុខងារពាក់ព័ន្ធបណ្តាវិស័យ ដើម្បីកំណត់អំពីមុខងារសមស្រប ដែលគួរប្រគល់ឱ្យ

ថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ

- កំណត់អំពីគោលការណ៍ណែនាំសម្រាប់ត្រួតពិនិត្យ និង សម្របសម្រួលការប្រគល់មុខងារខាងលើ ឱ្យមានដំណាក់កាលសមស្រប សំដៅធានាឱ្យមានអន្តរកាលយ៉ាងរលូន នៅក្នុងការប្រគល់មុខងារ និងធនធាន

- កំណត់អំពីការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធដំណើរការ និង នីតិវិធីនានាសម្រាប់ការអនុវត្តមុខងារ ដែលបានប្រគល់ឱ្យថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ

- កំណត់នីតិវិធី និងដំណើរការសម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តមុខងារ ដែលបានប្រគល់ពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ ។

ខ. ពិនិត្យឡើងវិញអំពីការអនុវត្តមុខងារ របស់ឃុំ សង្កាត់កន្លងមក ដើម្បី ÷

- វាយតម្លៃអំពីការប្រគល់មុខងារឱ្យឃុំ សង្កាត់សមស្រប ឬមិនសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- កំណត់អំពីការប្រគល់មុខងារបន្ថែមទៀតឱ្យឃុំ សង្កាត់ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងាររបស់ឃុំ សង្កាត់

- រៀបចំប្រព័ន្ធ រចនាសម្ព័ន្ធ និងនីតិវិធីនានាសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ឱ្យមានប្រសិទ្ធភាពខ្ពស់

- រៀបចំប្រព័ន្ធដំណើរការ និងគោលការណ៍ណែនាំនានាដើម្បីជម្រុញ និងបង្កលក្ខណៈឱ្យសហគមន៍មូលដ្ឋានចូលរួមនៅក្នុងកិច្ចការរបស់ឃុំ សង្កាត់ ។

គ. សម្របសម្រួលជាមួយដៃគូពាក់ព័ន្ធនានា ក្នុងការគាំទ្រដល់គម្រោងសាកល្បងនានា តាមថ្នាក់រដ្ឋបាលក្រោមថ្នាក់ជាតិដែលមានការពាក់ព័ន្ធដល់ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងមុខងារ ដោយបង្កើតឱ្យមានយន្តការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា សង្គមស៊ីវិល ដែលកំពុងគាំទ្រដល់ដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការលើកិច្ចការនានា ដែលស្ថិតក្រោមការទទួលខុសត្រូវ របស់អនុគណៈកម្មការ

ឃ.បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពី គ.ជ.វ.វ ។

**ប្រការ ៤.-**

អនុគណៈកម្មការសារពើពន្ធ និងហិរញ្ញវត្ថុ មានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| ១. រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. តំណាង ក្រសួងផែនការ | សមាជិក |
| ៤. តំណាង ក្រសួងកិច្ចការនារី | សមាជិក |
| ៥. តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧. តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៨. តំណាងលេខាធិការដ្ឋាននៃ គ.ជ.វ.វ | ជាលេខាធិការ |

តំណាងក្រសួង ស្ថាប័ន ដែលជាសមាជិកអនុគណៈកម្មការត្រូវមានឋានៈចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ។

អនុគណៈកម្មការសារពើពន្ធ និងហិរញ្ញវត្ថុមានតួនាទី ភារកិច្ចដូចខាងក្រោម ÷

ក. សិក្សាស្រាវជ្រាវ និងលើកសំណើអំពីគោលនយោបាយ ដើម្បីបង្កើត អនុវត្ត និងគាំទ្រដល់ការចាត់ចែងផ្នែកសារពើពន្ធ និងហិរញ្ញវត្ថុរបស់ថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ដោយ ៖

- បង្កើតឱ្យមានប្រាក់ចំណូលសមស្រប សម្រាប់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ដើម្បីឱ្យថ្នាក់រដ្ឋបាលទាំងនោះមានធនធានគ្រប់គ្រាន់អាចអនុវត្តមុខងារ និងអំណាចរបស់ខ្លួន
- កំណត់បរិមាណ និងប្រព័ន្ធនៃការផ្ទេរធនធានពីថវិកាថ្នាក់ជាតិទៅថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ
- កំណត់អំពីប្រាក់កម្រៃសម្រាប់ថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ដើម្បីអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មពីថ្នាក់ជាតិ
- រៀបចំឱ្យមានទ្រព្យសម្បត្តិ សម្រាប់ថ្នាក់រដ្ឋបាលក្រោមថ្នាក់ជាតិ
- រៀបចំនីតិវិធីសម្រាប់រៀបចំថវិការបស់ថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ
- កំណត់អំពីការគ្រប់គ្រង ប្រើប្រាស់ ត្រួតពិនិត្យសារពើពន្ធ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ប្រកបដោយគណនេយ្យភាព និងតម្លាភាព ។

ខ. ចំពោះសារពើពន្ធ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ក្នុងប្រព័ន្ធគ្រប់គ្រងរបស់ឃុំ សង្កាត់បច្ចុប្បន្នត្រូវ ៖

- ពិនិត្យ និងវាយតម្លៃឡើងវិញអំពីកិច្ចការសារពើពន្ធ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ជាមួយនឹងគោលនយោបាយដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- លើមូលដ្ឋាននៃការពិនិត្យ និងវាយតម្លៃខាងលើ ត្រូវសិក្សាពិចារណារៀបចំឱ្យមានគម្រោងដកពិសោធន៍សម្រាប់បង្កើតប្រភពចំណូលផ្ទាល់របស់ឃុំ សង្កាត់
- កំណត់ និងធានាការផ្តល់ប្រាក់កម្រៃឱ្យបានច្បាស់លាស់ និងសមស្រប ចំពោះការអនុវត្តមុខងារជាភ្នាក់ងាររបស់ឃុំ សង្កាត់
- សិក្សាអំពីលទ្ធភាពនានាក្នុងការបង្កើនបរិមាណនៃការផ្ទេរថវិកាថ្នាក់ជាតិទៅឃុំ សង្កាត់
- លើកកម្ពស់ការគ្រប់គ្រង ប្រើប្រាស់មូលនិធិឃុំ សង្កាត់ឱ្យមានគណនេយ្យភាព និងតម្លាភាព
- ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងការធ្វើសវនកម្មលើថវិកាឃុំ សង្កាត់ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ ។

គ. បង្កើតឱ្យមានយន្តការពិគ្រោះយោបល់ និងសហប្រតិបត្តិការឱ្យបានសមស្របរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដែលកំពុងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍន៍មូលដ្ឋាន ព្រមទាំងការកែទម្រង់កិច្ចការសារពើពន្ធ ហិរញ្ញវត្ថុ ដើម្បីរួមគ្នារៀបចំឱ្យបាននូវប្រព័ន្ធសមស្របមួយ ដែលទាំងអស់គ្នាអាចប្រើប្រាស់បានប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព នូវមូលនិធិសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងរដ្ឋបាលនានានៅក្រោមថ្នាក់ជាតិ ។

ឃ .បំពេញការងារផ្សេងទៀត ដែល គ.ជ.វ.វ ប្រគល់ជូន ។

**ប្រការ ៥.-**

អនុគណៈកម្មការផែនការមានសមាសភាព ដូចខាងក្រោម ៖

១. រដ្ឋលេខាធិការ ក្រសួងផែនការ ប្រធាន

២. រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣. តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤. តំណាង ក្រសួងកិច្ចការនារី — សមាជិក

៥. តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក

៦. តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក

៧. តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ — សមាជិក

៨. តំណាងលេខាធិការដ្ឋាននៃ គ.ជ.វ.វ — ជាលេខាធិការ

តំណាងក្រសួង ស្ថាប័ន ដែលជាសមាជិកអនុគណៈកម្មការត្រូវមានឋានៈចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ។

អនុគណៈកម្មការផែនការមានតួនាទី ភារកិច្ចដូចខាងក្រោម ÷

ក.សិក្សាស្រាវជ្រាវ និងលើកសំណើអំពីគោលនយោបាយ ដើម្បីបង្កើតប្រព័ន្ធកសាងផែនការ សម្រាប់ក្រុម ប្រឹក្សានៅថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ដោយ ÷

- ធានាឱ្យក្រុមប្រឹក្សាទាំងនោះក្លាយជាអាជ្ញាធរចម្បង ក្នុងការកសាងផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួន
- ធានាឱ្យក្រុមប្រឹក្សាទាំងនោះម្ចាស់ការក្នុងការជ្រើសរើស សម្រេចលើខ្លឹមសារផែនការអភិវឌ្ឍន៍របស់ខ្លួន និង កម្មវិធីវិនិយោគ
- កំណត់អំពីគោលការណ៍សម្រាប់ការធ្វើសហប្រតិបត្តិការក្នុងចំណោមក្រុមប្រឹក្សាប្រភេទដូចគ្នា ឬផ្សេងគ្នា ឬ ជាមួយក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាលក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- រៀបចំគោលការណ៍ឱ្យមានយន្តការចូលរួម ការពិគ្រោះយោបល់ក្នុងដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគខាងលើនេះ

ខ. អំពីប្រព័ន្ធ និងនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ដែលមានបច្ចុប្បន្នត្រូវ ÷

- ពិនិត្យ និងវាយតម្លៃឡើងវិញ ដើម្បីរៀបចំប្រព័ន្ធ និងនីតិវិធីឱ្យបានសាមញ្ញ ងាយស្រួល និងមានប្រសិទ្ធភាព
- ធានាឱ្យមានការចូលរួមពីសហគមន៍នៅមូលដ្ឋានក្នុងដំណើរការកសាង និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- លើកកម្ពស់គណនេយ្យភាព និងតម្លាភាពក្នុងការអនុវត្តគម្រោង និងនិរន្តរភាពនៃគម្រោងអភិវឌ្ឍន៍នានា ។

គ. បំពេញការងារផ្សេងទៀតដែល គ.ជ.វ.វ ប្រគល់ជូន ។

**ប្រការ ៦.-**

អនុគណៈកម្មការនគរូបនីយកម្ម និងព្រំប្រទល់ មានសមាសភាព ដូចខាងក្រោម ÷

១. រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ប្រធាន

២. រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ — អនុប្រធាន

៣. តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក

៤. តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក

៥. តំណាង ក្រសួងកិច្ចការនារី — សមាជិក

៦. តំណាង ក្រសួងផែនការ — សមាជិក

៧. តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ — សមាជិក

៨. តំណាងលេខាធិការដ្ឋាននៃ គ.ជ.វ.វ — ជាលេខាធិការ

តំណាងក្រសួង ស្ថាប័ន ដែលជាសមាជិកអនុគណៈកម្មការត្រូវមានឋានៈចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ។

អនុគណៈកម្មការនគរូបនីយកម្ម និងព្រំប្រទល់មានតួនាទី ភារកិច្ចសំខាន់ៗ ដូចខាងក្រោម ÷

- សិក្សាកំណត់លក្ខណៈវិនិច្ឆ័យអំពីទីក្រុង និងទីប្រជុំជន ដើម្បីរៀបចំគោលនយោបាយគ្រប់គ្រងទីក្រុង និងទីប្រជុំជន សម្រាប់ដាក់បញ្ចូលទៅក្នុងច្បាប់រៀបចំអង្គការ

- សិក្សាអំពីគោលនយោបាយនគរូបនីយកម្មនៅក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- គិតគូរអំពីផលប៉ះពាល់នៃកំណើនទីក្រុង ដោយសារកំណើនប្រជាជន និងចលនាចំណាកស្រុកពីជនបទមកទីក្រុង ឬ ទីប្រជុំជន និងការកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ដើម្បីផ្ដល់អនុសាសន៍អំពីការអភិវឌ្ឍទីប្រជុំជន និងជនបទ

- វាយតម្លៃផលប៉ះពាល់ និងទំនាក់ទំនងជាសក្ដានុពលនៃនគរូបនីយកម្មមកលើសេដ្ឋកិច្ច ការអភិវឌ្ឍ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ដីធ្លី ប្លង់គោលនៅក្នុងទីក្រុង ទីប្រជុំជន

- សិក្សាពិនិត្យឡើងវិញដើម្បីកំណត់ព្រំប្រទល់ទីក្រុង ទីប្រជុំជនឱ្យបានមុនការអនុម័តច្បាប់រៀបចំអង្គការ

- សិក្សាអំពីព្រំប្រទល់រវាងថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ដើម្បីសម្រួលដល់ការរៀបចំ ការគ្រប់គ្រងសម្រាប់ថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ

- សិក្សាផ្ដល់អនុសាសន៍អំពីការគ្រប់គ្រងប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ ឱ្យបានសមស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

- បំពេញការងារផ្សេងៗទៀត ដែល គ.ជ.វ.វ ប្រគល់ជូន ។

**ប្រការ ៧.-**

អនុគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ធនធានមនុស្ស មានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១. | រដ្ឋលេខាធិការ មុខងារសាធារណៈ | ប្រធាន |
| ២. | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. | តំណាង ទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. | តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | តំណាង ក្រសួងកិច្ចការនារី | សមាជិក |
| ៦. | តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧. | តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៨. | ប្រធាននាយកដ្ឋានបុគ្គលិករដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ | សមាជិក |
| ៩. | តំណាងលេខាធិការដ្ឋាននៃ គ.ជ.វ.វ | ជាលេខាធិការ |

តំណាងក្រសួង ស្ថាប័ន ដែលជាសមាជិកអនុគណៈកម្មការត្រូវមានឋានៈចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ។

អនុគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ធនធានមនុស្ស មានតួនាទី ភារកិច្ចដូចខាងក្រោម ÷

- សិក្សា និងផ្ដល់អនុសាសន៍អំពីការរៀបចំឱ្យមានបុគ្គលិកផ្ទាល់សម្រាប់រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិឱ្យបានសមស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

- សិក្សា និងផ្ដល់អនុសាសន៍អំពីគោលនយោបាយនានាក្នុងការផ្ទេរ ឬប្រគល់ បែងចែកបុគ្គលិករដ្ឋបច្ចុប្បន្នទៅឱ្យថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិឱ្យមានភាពរលូន

- សិក្សាអំពីគោលនយោបាយ និងនីតិវិធីនៃការជ្រើសរើសបុគ្គលិក ការរៀបចំមុខតំណែង បៀវត្ស និងប្រាក់ឧបត្ថម្ភ

សម្រាប់បុគ្គលិកនៅតាមថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ

- សហការជាមួយអ្នកពាក់ព័ន្ធនានា ធ្វើការសិក្សាពិចារណាអំពីប្រព័ន្ធ និងនីតិវិធីនៃការជ្រើសរើស ការគ្រប់គ្រង និងការប្រើប្រាស់បុគ្គលិក នៃគម្រោងកម្មវិធីនានា ដែលកំពុងគាំទ្រដល់ដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ចំពោះការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បច្ចុប្បន្ន ត្រូវធ្វើការវាយតម្លៃកំណត់ឡើងវិញអំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្មៀនឃុំ សង្កាត់

- សិក្សារៀបចំនូវប្រព័ន្ធបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិក ធនធានមនុស្សនៅតាមថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព

- រៀបចំផែនការ កម្មវិធី ខ្លឹមសារ និងសហការធ្វើការបណ្តុះបណ្តាលសម្រាប់ថ្នាក់រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ

- សហការផ្តល់ចំណេះដឹងដល់មន្ត្រីគ្រប់កម្រិតរបស់រាជរដ្ឋាភិបាលអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- សហការតាមដាន និងវាយតម្លៃអំពីការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិកតាមថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ

- រៀបចំកម្មវិធីអប់រំ និងផ្តល់ការយល់ដឹងដល់សាធារណជន អំពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- សិក្សា កំណត់គោលការណ៍សម្រាប់ការរៀបចំព្រឹត្តិបត្រ ឯកសារអប់រំផ្សព្វផ្សាយនានា ការរៀបចំគេហទំព័រ ការរៀបចំកម្មវិធីនានាតាមប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បំពេញការងារផ្សេងៗទៀតដែល គ.ជ.វ.វ ប្រគល់ជូន ។

**ប្រការ ៨.-**

ក្នុងការរៀបចំគោលនយោបាយ គោលការណ៍ និងការណែនាំសម្រាប់ការអនុវត្តនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ អនុគណៈកម្មការទាំងអស់ ជានិច្ចកាលត្រូវយកចិត្តទុកដាក់ ដើម្បីបញ្ជ្រាបការលើកកម្ពស់ដល់ការឆ្លើយតបនូវសេចក្តីត្រូវការរបស់នារី កុមារ និងក្រុមជនងាយរងគ្រោះ ។

## ជំពូកទី ៣

## អំពីរបៀបរបបការងាររបស់អនុគណៈកម្មការ

**ប្រការ ៩.-**

អនុគណៈកម្មការនីមួយៗនៃ គ.ជ.វ.វ ត្រូវបំពេញការងារ ក្រោមការសម្របសម្រួលពីក្រុមការងារ គ.ជ.វ.វ ។

អនុគណៈកម្មការនីមួយៗ ត្រូវសិក្សាវាយតម្លៃ និងផ្តល់នូវសេចក្តីរាយការណ៍អំពីកិច្ចការ និងសកម្មភាពរបស់ខ្លួន ជូន គ.ជ.វ.វ តាមរយៈក្រុមការងារ គ.ជ.វ.វ ផ្អែកតាមភារកិច្ចដែលបានកំណត់ ។

**ប្រការ ១០.-**

ករណីកិច្ចការណាមួយ មានការពាក់ព័ន្ធដល់សមត្ថកិច្ចរបស់អនុគណៈកម្មការច្រើន ប្រធានក្រុមការងារ គ.ជ.វ.វ ត្រូវសុំការសម្រេចពីប្រធាន គ.ជ.វ.វ ដើម្បីប្រគល់កិច្ចការនេះ ឱ្យទៅអនុគណៈកម្មការណាមួយទទួលខុសត្រូវ ។

កិច្ចការនេះ ត្រូវដាក់ជូនកិច្ចប្រជុំរួមរបស់អនុគណៈកម្មការដែលមានការពាក់ព័ន្ធ ក្រោមអធិបតីភាពប្រធានអនុ

គណៈកម្មការ ដែលជាអ្នកទទួលខុសត្រូវកិច្ចការខាងលើ ដើម្បីផ្ដល់អនុសាសន៍រួមគ្នា រួចហើយត្រូវប្រគល់ឱ្យប្រធានអនុគណៈកម្មការនោះ រៀបចំដាក់ជូនអង្គប្រជុំ គ.ជ.វ.វ សម្រេច។

**ប្រការ ១១.-**

ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារ គ.ជ.វ.វ តំណាងក្រសួង ស្ថាប័ន ក្នុងអនុគណៈកម្មការនីមួយៗ អាចស្នើរដ្ឋមន្ត្រី ឬប្រធានស្ថាប័នរបស់ខ្លួន ដើម្បីចាត់មន្ត្រីបច្ចេកទេសក្នុងក្រសួង ស្ថាប័នខ្លួន ឱ្យជួយការងារក្នុងអនុគណៈកម្មការនីមួយៗ តាមសំណូមពរការងារ ឬ/និង អាចបង្កើតក្រុមការងារដើម្បីជួយការងារ ឬអាចស្នើឱ្យក្រសួង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធឱ្យចូលរួមក្នុងអនុគណៈកម្មការតាមការចាំបាច់។

**ប្រការ ១២.-**

ក្រុមការងារ គ.ជ.វ.វ ត្រូវធ្វើការសម្របសម្រួលការគាំទ្រខាងគោលនយោបាយ និងបច្ចេកទេសដល់អនុគណៈកម្មការនីមួយៗ ដោយ ៖

- ផ្ដល់ការពិគ្រោះ ពិភាក្សាអំពីគោលនយោបាយ គោលការណ៍ និងការងារបច្ចេកទេសដែលមានការគាំទ្រដល់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ
- ស្វះស្វែងរកការគាំទ្រខាងបច្ចេកទេស ហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារពីប្រភពក្នុង និងក្រៅប្រទេស ដើម្បីជួយគាំទ្រដល់សកម្មភាពអនុគណៈកម្មការនីមួយៗ
- សម្របសម្រួលឱ្យមានការបណ្ដុះបណ្ដាល និងកសាងសមត្ថភាពដល់អនុគណៈកម្មការ ក្រុមការងារ ឬមន្ត្រីជំនាញនៃអនុគណៈកម្មការ
- សម្របសម្រួលឱ្យអនុគណៈកម្មការនីមួយៗ រៀបចំកម្មវិធី និងគម្រោងការងារសម្រាប់អនុគណៈកម្មការរបស់ខ្លួន
- សម្របសម្រួលឱ្យមានកិច្ចប្រជុំរបស់អនុគណៈកម្មការនីមួយៗ ឬកិច្ចប្រជុំរួមរវាងអនុគណៈកម្មការពីរ ឬច្រើន ក្នុងករណី ដែលការងារមានការពាក់ព័ន្ធដល់អនុគណៈកម្មការច្រើន
- សម្របសម្រួលអំពីពេលវេលា ទីកន្លែង ការកោះប្រជុំ និងការងាររដ្ឋបាលផ្សេងៗទៀត របស់អនុគណៈកម្មការនីមួយៗ តាមការស្នើសុំពីប្រធានអនុគណៈកម្មការ។

**ប្រការ ១៣.-**

គ្រប់បញ្ហាដែលអនុគណៈកម្មការនីមួយៗ ដាក់ជូន គ.ជ.វ.វ ពិនិត្យ ពិភាក្សា និងអនុម័ត ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដាក់ជូនក្រុមការងារ និង គ.ជ.វ.វ ពិនិត្យ សម្រេច។

**ប្រការ ១៤.-**

លេខាធិការដ្ឋាន គ.ជ.វ.វ ត្រូវផ្ដល់ការគាំទ្រផ្នែកលេខាធិការជូនក្រុមការងារ និងអនុគណៈកម្មការនានានៃ គ.ជ.វ.វ ។

**ប្រការ ១៥.-**

អនុគណៈកម្មការនីមួយៗត្រូវធ្វើការប្រជុំជាសាមញ្ញម្ដង ក្នុងមួយខែ។ ក្នុងករណីចាំបាច់ ប្រធានអនុគណៈកម្មការអាចកោះប្រជុំវិសាមញ្ញបាន។

**ប្រការ ១៦.-**

ក្នុងករណីអនុគណៈកម្មការណាមួយពន្យារពេល ឬខកខានមិនបានធ្វើសេចក្ដីសម្រេចលើឯកសារណាមួយ លើសពីកិច្ចប្រជុំសាមញ្ញមួយរបស់ខ្លួន ក្រុមការងារត្រូវរាយការណ៍អំពីហេតុផលនៃការពន្យារពេលនេះ ជូនដល់កិច្ចប្រជុំបន្ទាប់របស់ គ.ជ.វ.វ ដើម្បីពិនិត្យ និងសម្រេច ។

## ជំពូកទី ៤
## គោលការណ៍នៃការអនុវត្តការកិច្ច

**ប្រការ ១៧.-**

ក្នុងការអនុវត្តការងារ អនុគណៈកម្មការនីមួយៗត្រូវផ្អែកលើគោលការណ៍ និងទស្សនទាន ដូចខាងក្រោម ÷

- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជា
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- គោលការណ៍ទូទៅនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- កម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា
- ច្បាប់ និងលិខិតបទដ្ឋានជាធរមាននៅកម្ពុជា ។

ក្នុងករណីពិនិត្យឃើញមានច្បាប់ និងលិខិតបទដ្ឋានណាដែលមិនសមស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ អនុគណៈកម្មការត្រូវលើកសំណើមក គ.ជ.វ.វ ដើម្បីស្នើធ្វើវិសោធនកម្ម ឬកែសម្រួលឱ្យបានសមស្រប ។

**ប្រការ ១៨.-**

ក្នុងការផ្ដល់នូវអនុសាសន៍នានា អនុគណៈកម្មការនីមួយៗ ត្រូវ ÷

- គាំទ្រគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ លើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- លើកទឹកចិត្ត និងគាំទ្រឱ្យមានការពិគ្រោះយោបល់ជាអន្តរក្រសួង និងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យមានការព្រមព្រៀងគ្នាលើគោលនយោបាយ និងគោលការណ៍នៃកិច្ចការរបស់អនុគណៈកម្មការ
- ពិនិត្យឡើងវិញ និងកំណត់អាទិភាព និងដំណាក់កាលនៃសកម្មភាពរបស់ខ្លួន
- បង្កើតឱ្យមាននូវវេទិកាសម្រាប់ការពិភាក្សារវាងអនុគណៈកម្មការជាមួយសង្គមស៊ីវិល វិស័យឯកជន និងក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីឱ្យមានការយោគយល់គ្នា និងព្រមព្រៀងគ្នា
- បង្កើតឱ្យមាននូវវេទិកាសម្រាប់ការពិភាក្សារវាងអនុគណៈកម្មការ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីឱ្យមានការយោគយល់គ្នា និងព្រមព្រៀងគ្នា និងដើម្បីលើកទឹកចិត្ត និងសម្របសម្រួលការគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងផ្នែកផ្សេងទៀត
- ពិនិត្យឡើងវិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន សេចក្ដីណែនាំ ឬកិច្ចព្រមព្រៀងផ្សេងទៀតដែលមានស្រាប់ ទាក់ទងទៅនឹងកិច្ចការស្ថិតនៅក្រោមតួនាទី និងភារកិច្ចរបស់ខ្លួន

- រៀបចំអនុសាសន៍លើវិសោធនកម្ម ឬការតាក់តែងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន សេចក្តីណែនាំ ឬកិច្ចព្រមព្រៀងថ្មីផ្សេងៗទៀត ដើម្បីគាំទ្រដល់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ ១៩.-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី..២៧...ខែ..[illegible]..ឆ្នាំ២០០៧*

**ជ.គណៈកម្មាធិការជាតិដឹកនាំការងារ**
**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**
**ប្រធាន**

**[illegible]**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *សមាជិក គ.ជ.វ.វ*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *ដូចប្រការ ៣-៤-៥-៦*
- *ឯកសារ-កាលប្បវត្តិ*